# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែសីហា ឆ្នាំ២០១៤
## និងទិសដៅការងារ ខែកញ្ញា ឆ្នាំ២០១៤

(ពីថ្ងៃទី៣១/០៧/២០១៤ ដល់ ៣១/០៨/២០១៤)

ដោយផ្អែកលើផែនការសកម្មភាពអនុវត្តទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆមាសទី២ ឆ្នាំ២០១៤ និង ទិសដៅការងារ ដែលបានដាក់ចេញកាលពីខែកក្កដាឆ្នាំ២០១៤ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីរួមចំណែកអនុវត្ត "គោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើក កម្ពស់សុខុមាលភាពប្រជាពលរដ្ឋទទួលបានលទ្ធផលដូចខាងក្រោម ។

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អង្គភាពអនុវត្តន៍ច្បាប់ រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន, ស្នងការដ្ឋាននគរបាល និង កងរាជអាវុធហត្ថ រាជធានី-ខេត្ត ដែលបានរាយការណ៍ពីលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរជួញដូរនិងប្រើប្រាស់គ្រឿងញៀន បានកើតមាននៅ រាជធានីភ្នំពេញ, ខេត្ត ព្រះសីហនុ, កណ្តាល, តាកែវ, កំពង់ស្ពឺ, កំពង់ឆ្នាំង, កំពង់ចាម, ព្រៃវែង, ស្វាយរៀង, ស្ទឹងត្រែង, រតនគិរី, កំពត, បាត់ដំបង, បន្ទាយមានជ័យ និង ខេត្តពោធិ៍សាត់ ។

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបបានក្នុងខែសីហានេះ កត់សំគាល់ឃើញមាន ១ ករណី មេតំហ្វេតាមីន ICE ដែលមន្ទីរប្រឆាំងគ្រឿងញៀន បានសហការបង្ក្រាបដោយជាមួយកម្លាំងនៃស្នងការដ្ឋាននគរ-បាលខេត្តស្ទឹងត្រែង ព្រមទាំងចាប់យកមេតំហ្វេតាមីន ICE ចំនួន ១.៧៣០,១៧ ក្រាម និងឃាត់ខ្លួនឈ្មួញគ្រឿង ញៀនជនជាតិឡាវមួយនាក់ ។

ដោយឡែក ខេត្តពោធិ៍សាត់ កម្លាំងនគរបាលស្រុកវាលវែង បានចុះបង្ក្រាបទីតាំងកប់លាក់ ប្រេងម្រះព្រៅភ្នំ ចំនួន ១៤១ បីដុង នៅផ្ទះឈ្មួញស្ថិតក្នុងភូមិក្រាំងរងៀង ឃុំអន្លង់រាប ស្រុកវាលវែង ដែលឈ្មួញបានជីកកប់លាក់ ក្នុងដី (ពេលជីកកកាយបែកអស់ពីរបីដុង នៅសល់ជាក់ស្តែង **១៣៩** បីដុង) ។

## II. អំពីការងារដឹកនាំ និង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំ ដឹកនាំបញ្ហាលើការងារជាគោលសំខាន់ៗ ជាអាទិ៍ :

- ជំរុញការរៀបចំកម្មវិធី ប្រឡងគូរគំនូរអប់រំពីបញ្ហាគ្រឿងញៀន នៅតាមខេត្តគោលដៅមួយចំនួន ។
- ជំរុញការរៀបចំអនុក្រឹត្យនានាពាក់ព័ន្ធនឹងការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។
- សហការជាមួយក្រសួងពាក់ព័ន្ធ ជួយរៀបចំផែនការត្រួតពិនិត្យគ្រឿងញៀនរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ។
- រៀបចំកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។
- ជំរុញការផលិតស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមណ្ឌលសុខភាពដែលបានរៀបចំរួច សម្រាប់ការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនផ្អែកលើសហគមន៍ នៅរាជធានីភ្នំពេញ ។
- បង្កើតគណៈកម្មាធិការជាតិ ទទួលបន្ទុកកិច្ចការព្យាបាល ថែទាំបន្ត ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និសមាហរណកម្មអ្នកញៀនគ្រឿងញៀន ។
- បើកវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពជំនាញ ដល់មន្ត្រីអនុវត្តន៍ច្បាប់នៅថ្នាក់ក្រោមជាតិចាប់ពីថ្នាក់ខេត្ត រហូតដល់ថ្នាក់នគរបាលប៉ុស្តិ៍រដ្ឋបាល ។
- បើកវគ្គបណ្តុះបណ្តាលកងយោធពលខេមរភូមិន្ទនៅតាមបណ្តាភូមិភាគ និងវរសេនាតូចការពារព្រំដែន ។
- រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន របស់ខេត្តនៅជាប់ព្រំដែនកម្ពុជា- ឡាវ ។
- ជំរុញការកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- កែសម្រួលសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ។
- រៀបចំដាក់បញ្ចូលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ ។

### ២. អំពីលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

#### ២.១. ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ បដិសេធគ្រឿងញៀន

ផ្តើមចេញពីគោលការណ៍ដឹកនាំរបស់ ឯកឧត្តម ឧបនាយរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ក៏ដូចជាផែនការអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពីខែកក្កដា ឆ្នាំ២០១៤ កន្លងទៅ ក្រសួង-ស្ថាប័នជាសមាជិក និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយក្នុងកម្មវិធីប្រចាំថ្ងៃ-សប្តាហ៍-ខែ, ការអប់រំនៅតាមសហគមន៍ ទទួលបានលទ្ធផលដូចមានក្នុងតារាងឧបសម្ព័ន្ធទី១ ។

**ក្នុងនោះ** លទ្ធផលដែលបានអនុវត្តដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រួមមាន ៈ

- ចូលរួមផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន នៅក្នុងកម្មវិធី " យុវជនថ្ងៃនេះ "ក្រោមប្រធានបទ "ការចូលរួមរបស់យុវជនដើម្បីទប់ស្កាត់ និងបង្ការការប្រើប្រាស់គ្រឿងញៀន "របស់អគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន (ថ្ងៃទី០៤/៨/២០១៤) ។
- សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកោះកុង រៀបចំកម្មវិធីប្រឡងផ្ដាច់ព្រ័ត្រ "ការគូរគំនូរប្រឆាំងគ្រឿងញៀន" ព្រមទាំងប្រកាសលទ្ធផល និងផ្ដល់រង្វាន់ដល់អ្នកជាប់ចំណាត់ថ្នាក់ ។
- ចូលរួមប្រជុំអ្នកពាក់ព័ន្ធ តាមការអញ្ជើញរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព ដើម្បីពិភាក្សាលើប្រធានបទស្តីពី ការធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងស្រវឹង ក្នុងគោលបំណងបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន (២១/៨/២០១៤) ។
- ចុះផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងសិក្ខាសាលាថ្នាក់ជាតិ " ស្តីពីការសម្របសម្រួលជួយគាំទ្រដល់ការអនុវត្តគម្រោងភាពជាដៃគូ នៃជំនួយផ្នែកយុត្តិធម៌សហគមន៍ នៅកម្ពុជា" ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កាលពីថ្ងៃទី២៩/៨/២០១៤ (អ្នកចូលរួម ៩១ នាក់ មន្ត្រីស្ថាប័នពាក់ព័ន្ធ និងមន្ត្រីរបស់ខេត្ត) ។
- បន្តអនុវត្តកម្មវិធីសម្រាប់ប្រិយមិត្តអ្នកអានគេហទំព័រ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រចាំ **ខែសីហា** មានប្រិយមិត្តអ្នកអានចំនួន **៧៦៤** ដង ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន នៅតាមសហគមន៍ ដែលបានអនុវត្តដោយក្រសួង-ស្ថាប័ន ព្រមទាំងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន **០៦** គឺ ខេត្តប៉ៃលិន, ស្វាយរៀង, កណ្តាល, បាត់ដំបង, ឧត្តរមានជ័យ, កំពង់ស្ពឺ នៅក្នុងខែសីហាឆ្នាំ២០១៤នេះ មានមហាជនចូលរួមប្រមាណ **៣៣.០០១** នាក់ លើ **៩១.៩៦៣** នាក់ [(1)] នៃខែកក្កដា ឆ្នាំ២០១៤ ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១ ។

## ***២.២. ការព្យាបាល ស្តារនីតិសម្បទា ផ្តល់ទិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន***

- ***ការកាត់បន្ថយគ្រោះថ្នាក់***
  - ✓ សហការជាមួយក្រសួងសុខាភិបាល, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ និងអង្គការ ខាន់ណា រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការពង្រឹងបរិយាកាសគាំទ្រដល់ក្រុមប្រើប្រាស់គ្រឿងញៀនដោយចាក់ និងក្រុមប្រឈមមុខខ្ពស់ កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ នៅសណ្ឋាគារណាហ្គាវើល (អ្នកពាក់ព័ន្ធចូលរួម ៧៥ រូប) ។

[1] សកម្មភាពផ្សព្វផ្សាយអប់រំ មានការថយចុះដោយសាររដូវវស្សាកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុននានា ត្រូវផ្អាកដំណើរការបណ្តោះអាសន្ន

- ✓ សហការជាមួយក្រសួងសុខាភិបាល, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តបន្ទាយមានជ័យនិងខេត្តប៉ៃលិន, អង្គការ FHI360 និងសាកលវិទ្យាល័យ កាលីហ្វ័រញ៉ា សាន់ហ្វ្រាន់ស៊ីស្កូ ដើម្បីរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ និងចាប់ផ្តើមអនុវត្តគម្រោងកម្មវិធីបង្ការមេរោគអេដស៍ និងគ្រឿងញៀននៅកម្ពុជា

- ✓ ដែលធ្វើនៅខេត្តប៉ៃលិន (ថ្ងៃទី២០/៨/២០១៤ អ្នកចូលរួម ៦០ រូប) និងនៅខេត្តបន្ទាយមានជ័យ (ថ្ងៃទី២១/៨/ ២០១៤ អ្នកចូលរួម ៦០ រូប) ។
- ✓ សហការជាមួយក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំចងក្រងព័ត៌មានស្តីពីការប្រើបំពានគ្រឿងញៀន និងការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅកម្ពុជា ។
- ✓ បានចូលរួមពិនិត្យលើលិខិតជូនដំណឹងស្តីពីការរៀបចំកិច្ចពិភាក្សាបើកចំហថ្នាក់ជាតិ ស្តីពីការរៀបចំកំណត់សំគាល់ទស្សនទានអំពីមេរោគអេដស៍ (ដើម្បីក្តាប់បានពីបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន) ។
- ✓ បានជួបប្រជុំជាមួយក្រុមការងារបច្ចេកទេស (PSI) របស់កម្មវិធី HAARP វៀតណាម ដើម្បីធ្វើការវាយតម្លៃគម្រោង HAARP មុនពេលគម្រោងនេះត្រូវបញ្ចប់អាណត្តិរបស់ខ្លួនក្នុងឆ្នាំ២០១៤ ។

- ***ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន***

ការងារនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងសុខភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បី ៖

- ✓ សហការជាមួយក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចុះជួបពិភាក្សាជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ និង ខេត្តសៀមរាប ដើម្បីពិនិត្យពីលទ្ធភាពក្នុងការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាព និងកាត់បន្ថយរាល់ការរិះគន់នានា ពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។
- ✓ ចូលរួមជាមួយក្រសួងសុខាភិបាល ដើម្បីពិនិត្យ កែសម្រួល លើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តកម្មវិធីព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ដែលព្រាងដោយអង្គការ UNODC ប្រចាំនៅកម្ពុជា ។

ដោយឡែក **នៅក្រៅប្រទេស** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានដឹកនាំសិក្ខាកាមទៅទទួលវគ្គបណ្តុះបណ្តាលលើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅប្រទេសវៀតណាម កាលពីថ្ងៃទី ២៤-២៩/៨/២០១៤ ដែលមានសមាសភាពមកពីក្រសួង និងខេត្តពាក់ព័ន្ធចំនួន ២១ រូប ។

## ***២.៣. ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់***

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់លើការពង្រឹងប្រសិទ្ធភាពការអនុវត្តច្បាប់ តាមរយៈសកម្មភាពដូចខាងក្រោម ៖

- ✓ បើកវគ្គបណ្ដុះបណ្ដាលមន្ត្រីអនុវត្តន៍ច្បាប់រាជធានីភ្នំពេញ ១២ រូប (វគ្គទី២ឆ្នាំ២០១៤) ស្ដីពីការពង្រឹងសមត្ថភាពក្នុងការត្រួតពិនិត្យគ្រឿងញៀន តាមប្រព័ន្ធកុំព្យូទ័រ (CBT) ពីថ្ងៃទី០៤-០៨ខែសីហា ឆ្នាំ២០១៤ ។
- ✓ បានសហការជាមួយអង្គការ UNODC រៀបចំកិច្ចប្រជុំស្ដីពីការចង្អុលបង្ហាញបច្ចេកវិទ្យាថ្មី ដែលជួយ

ដល់ការប្រយុទ្ធប្រឆាំងគ្រឿងញៀននិងឧក្រិដ្ឋកម្មឆ្លងដែន (ធ្វើនៅភ្នំពេញ ថ្ងៃទី០៥ ខែសីហា ឆ្នាំ ២០១៤) ។
- ✓ រៀបចំវគ្គបណ្ដុះបណ្ដាល (វគ្គ១/ឆ្នាំ២០១៤) ដល់សិក្ខាកាមជា ចៅសង្កាត់ និងនាយនគរបាលប៉ុស្តិ៍ ចំនួន ៦០ រូប មកពីខណ្ឌ ចំនួន ៥ គឺ ខណ្ឌឬស្សីកែវ, ដង្កោ, សែនសុខ, ជ្រោយចង្វា និង ព្រែកព្នៅ ចាប់ពីថ្ងៃទី១៤-១៥/៨/២០១៤ ។
- ✓ រៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ (គាំទ្រដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ ONCB) ដល់មន្ត្រីអនុវត្តន៍ច្បាប់នៃខេត្តព្រះវិហារ ចំនួន៥០រូប (ថ្ងៃទី២៥-២៦ /៨/២០១៤), មន្ត្រីអនុវត្តន៍ច្បាប់នៃខេត្តស្ទឹងត្រែង ចំនួន៥០ រូប (ថ្ងៃទី២៨-២៩/៨/២០១៤) ។
- ✓ រៀបចំវគ្គបណ្ដុះបណ្ដាលចំណេះដឹងជាមូលដ្ឋានពីគ្រឿងញៀន និង ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដល់កងយោធពលខេមរភូមិន្ទ នៅយោធភូមិភាគ៥ (ធ្វើនៅខេត្តបាត់ដំបង ថ្ងៃទី២៦/៨/ ២០១៤ មានសិក្ខាកាមចូលរួម ១៥០ នាក់), យោធភូមិភាគ៤ (ធ្វើនៅខេត្តសៀមរាប ថ្ងៃទី២៨/៨/ ២០១៤ មានសិក្ខាកាមចូលរួម ១៥០ នាក់) ។
- ✓ រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន របស់ខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ (ថ្ងៃទី១២/៨/២០១៤ មន្ត្រីចូលរួម ២០៣ រូប) ។

**នៅក្រៅប្រទេស** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានដឹកនាំសិក្ខាកាម ដែលមកពីរាជធានី-ខេត្តគោលដៅ និងក្រសួងពាក់ព័ន្ធ ចំនួន ៣០ រូប ទៅទទួលវគ្គបណ្ដុះបណ្ដាលស្ដីពីការអនុវត្តច្បាប់គ្រឿងញៀន នៅទីក្រុងគុនមិញ ខេត្តយូណាន ប្រទេសចិន ពីថ្ងៃទី១២ ខែសីហា ដល់ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ ។

**ដោយឡែក ក្រសួងការពារជាតិ** ក៏បានបើកវគ្គបណ្ដុះបណ្ដាលផ្ទាល់ដល់សិក្ខាកាម នៅយោធភូមិភាគ៤ ចំនួន ១.៤២៣ នាក់ និង យោធភូមិភាគ៥ ចំនួន ១.៦៨៤ នាក់ ស្ដីពីចំណេះដឹងជាមូលដ្ឋានពីគ្រឿងញៀន និង ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

ទន្ទឹមនឹងការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់ មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទ បានបន្តយកចិត្តទុកដាក់ចូលរួមសហការបង្ក្រាបបទល្មើសគ្រឿងញៀន សំដៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម :

- បទល្មើសគ្រឿងញៀន សរុប ***១០៧ ករណី*** លើ ១១២ ករណី នៃខែកក្កដា ឆ្នាំ២០១៤
- ជនសង្ស័យ ឃាត់ខ្លួន សរុប ***២៤៥*** នាក់ លើ ៣១៧ នាក់ នៃខែកក្កដា ឆ្នា២០១៤

  ក្នុងចំនួនបទល្មើសគ្រឿងញៀន ***១០៧ ករណី*** និង ជនសង្ស័យទាំង ***២៤៥ នាក់*** ខាងលើគឺ :

- ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយកងនគរបាល ***៨១ ករណី***, ជនសង្ស័យ ***១៦៧ នាក់*** (ស្រី ២២ នាក់)
- ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយកងរាជអាវុធហត្ថ ***២៦ ករណី***, ជនសង្ស័យ ***៧៨ នាក់*** (ស្រី *១០* នាក់)

- ក្នុងចំនួនជនសង្ស័យ ដែលបានឃាត់ខ្លួនទាំង ២៤៥ នាក់ ខាងលើ មាន ០៣ សញ្ជាតិ គឺ ខ្មែរ ២៤១ នាក់ (ស្រី ៣១ នាក់), វៀតណាម ០៣ នាក់ (ស្រី ០១ នាក់), ឡាវ ០១ នាក់ (ប្រុស) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូង រាជធានី-ខេត្ត ។
- **វត្ថុតាងគ្រឿងញៀនចាប់យក រួមមាន** មេតំហ្វេតាមីន WY ២៩៣,៤៨ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ (ICE) ១.៩២០,៩៩ ក្រាម, អ៊ិចស្តាស៊ី ២,១០ ក្រាម, កញ្ឆា ១១២១ ដើម, សារធាតុសង្ស័យគ្រឿងញៀន ១១០,៤២ ក្រាម ។
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន** បានចាប់យករួមមាន ម៉ូតូ ១៥ គ្រឿង, រថយន្ត ៣ គ្រឿង, ប្រាក់កម្ពុជា ១.១១៤.៣០០ រៀល, ប្រាក់ថៃ ៤០ បាត, ប្រាក់អាមេរិក ២២១ ដុល្លារ, ប្រាក់វៀតណាម ១០.០០០ ដុង **ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២** ។

**ដោយឡែក** ជនសង្ស័យចាប់តាមដីកា មាន ៣ ដីកា = មនុស្ស ៣ នាក់ (ប្រុស) ជនជាតិខ្មែរ ។

**ជាមួយនេះ** មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានា និងតុលាការរាជធានី-ខេត្ត នៅក្នុងខែសីហា ឆ្នាំ២០១៤ នេះ សរុបចំនួន ២៧ ករណី = ៣១ សំណាក ។ ក្នុងនោះ **:**

- ✓ **សំណាកវិជ្ជមានសារធាតុញៀន មាន ២៤ ករណី = ២៧ សំណាក គឺ :**
  មេតំហ្វេតាមីន ICE ២១ សំណាក = ៦៧,៧៤ %,
  មេតំហ្វេតាមីន WY ០៤ សំណាក = ១២,៩០ %
  កេតាមីន = ០១ សំណាក = ៣,២២ %, កូកាអ៊ីន ០១ សំណាក = ៣,២២ %
- ✓ **សំណាកអវិជ្ជមានសារធាតុញៀន ០៣ ករណី = ០៤ សំណាក**

ក្រៅពីការងារកោសលវិច័យ មន្ទីរពិសោធន៍គ្រឿងញៀន បានទទួលនូវ ៖

- ✓ ឧបករណ៍សម្រាប់ធ្វើតេស្តទឹកមូត្ររកសារធាតុ មេតំហ្វេតាមីន ចំនួន ៣.០០០ តេស្ត ពីក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) កាលពីថ្ងៃទី២៥/៨/២០១៤ ។
- ✓ ម៉ាស៊ីនវិភាគគ្រឿងញៀន ប្រភេទយួរដៃ ០១ គ្រឿង ពីក្រុមហ៊ុន AAP INTERNATIONAL CAMBODIA CO.,LTD ។

## ***២.៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ***

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឲ្យនាំចូលនៅក្នុងខែសីហាឆ្នាំ២០១៤នេះ មានដូចតទៅ ៖

- សារធាតុគីមីចម្រុះ សរុបចំនួន **១.៣៣០.២៦០** គ.ក្រ **៤.៩៥១** លីត្រ ក្នុងនោះ
  - ✓ សារធាតុគីមី ដែលចេញអាជ្ញាបណ្ណដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម មាន ៦៣៧.១៦០ គ.ក្រ និង ៥១ លីត្រ (ពាក់ព័ន្ធនឹងតារាងទីIV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន)
  - ✓ សារធាតុគីមី ដែលចេញអាជ្ញាបណ្ណដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ៦៩៣.១០០ គ.ក្រ ៤.៩០០ លីត្រ (ពាក់ព័ន្ធនឹងតារាង IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន)

  - ✓ វត្ថុធាតុដើមប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលចេញអាជ្ញាបណ្ណដោយក្រសួងសុខាភិបាល មាន ២២៥ គ.ក្រ (ពាក់ព័ន្ធនឹងតារាង III នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន)
- ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលនាំចូលដោយក្រសួងសុខាភិបាល មាន ០១ គ.ក្រ ៣៩៨,១ ក្រាម ១.៤០៩ មិល្លីក្រាម ៦០០ មីក្រូក្រាម (ពាក់ព័ន្ធនឹងតារាង II តារាង III នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន)

**ជាមួយនេះ អគ្គលេខាធិការដ្ឋាន** បាន ៖

- បន្តការរៀបចំបែបបទប្រគល់ ប្រេងម្រះព្រៅភ្នំ ចំនួន ១.៧០០ លីត្រ និង ១២៣ គ.ក្រ ទៅក្រសួងឧស្សាហ-កម្ម និងសិប្បកម្ម ដើម្បីបន្តការគ្រប់គ្រង និងចាត់ចែងតាមសមត្ថកិច្ច ។
- រៀបចំគណៈកម្មការចម្រុះមួយក្រុម ដើម្បីសហការជាមួយខេត្តពោធិ៍សាត់ ក្នុងការស្រាវជ្រាវករណី ប្រេងម្រះព្រៅភ្នំ ចំនួន ១៣៩ ប៊ីដុង ដែលរកឃើញនៅចំណុចភូមិក្រាំងរងៀង ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១៧, ១៨, ២៦ ខែសីហា ឆ្នាំ២០១៤ ។

## *២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសជិតខាង*

- សម្របសម្រួលជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀនវៀតណាម ដើម្បីបញ្ជូនមន្ត្រីទៅទទួលវគ្គបណ្តុះបណ្តាលលើការងារព្យាបាលអ្នកញៀនគ្រឿងញៀន នៅប្រទេសវៀតណាម ពីថ្ងៃទី ២៤-២៩/៨/២០១៤ ដែលមានមន្ត្រីពាក់ព័ន្ធចូលរួម ២១ រូប ។
- សម្របសម្រួលជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ របស់ខេត្តព្រះវិហារ ចំនួន ៥០ រូប (ថ្ងៃទី២៥-២៦/៨/២០១៤) និងខេត្តស្ទឹងត្រែង ចំនួន ៥០ រូប (ថ្ងៃទី២៨-២៩/៨/២០១៤) ។

**ដោយឡែក ៖**

- ខេត្តមណ្ឌលគិរី បានជួបប្រជុំជាមួយស្នងការដ្ឋាននគរបាលខេត្តដាក់ឡាក់ (វៀតណាម) ដើម្បីបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន កាលពីថ្ងៃទី០៨/៨/២០១៤ (ធ្វើនៅខេត្តមណ្ឌលគិរី ភាគីកម្ពុជា មាន ៣៣ រូប) ។
- ខេត្តឧត្តរមានជ័យ បានប្រជុំរវាងការិយាល័យ BLO ក្រុងសំរោង ជាមួយការិយាល័យ BLO ស្រុកកាប់ធឺន ខេត្តសុរិន ប្រទេសថៃ ដើម្បីផ្លាស់ប្តូរសភាពការណ៍គ្រឿងញៀនឆ្លងកាត់ព្រំដែន (ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ (ធ្វើនៅការិយាល័យ BLO ស្រុកកាប់ធឺន ភាគីកម្ពុជា មាន១៥ រូប) ។

## *២.៦. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ*

- សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីបញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន ០២ រូប ទៅចូលរួមសិក្ខាសាលាថ្នាក់តំបន់ ស្តីពី កម្មវិធី Global SMART ។
- បានសម្របសម្រួលជូនក្រុមការងារបច្ចេកទេស (PSI) របស់កម្មវិធី HAARP វៀតណាម ជួបជាមួយកម្ពុជា ធ្វើការវាយតម្លៃគម្រោង HAARP ។
- សម្របសម្រួលជាមួយអង្គការ UNODC រៀបចំកិច្ចប្រជុំស្តីពីការចង្អុលបង្ហាញបច្ចេកវិទ្យាថ្មី ដែលជួយដល់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន (ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥/៨/២០១៤) ។
- សម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនចិន ដើម្បីបញ្ជូនមន្ត្រីអនុវត្តន៍កម្ពុជាចំនួន ៣០ រូប ទៅទទួលវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តច្បាប់គ្រឿងញៀន ពីថ្ងៃទី១២ ខែសីហា ដល់ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ នៅទីក្រុងគុនមិញ ខេត្តយូណាន ប្រទេសចិន ។

### ២.៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ដើម្បីពង្រឹងនិងពង្រីកលទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រពហុវិស័យឲ្យមានប្រសិទ្ធភាព អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន ៖

- បន្តការកែសម្រួលអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- បន្តពិនិត្យលើការរៀបចំដាក់បញ្ចូលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅក្នុងអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ ។
- ពិនិត្យ កែសម្រួល លើសេចក្តីព្រាងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ។
- បន្តរៀបចំអនុក្រឹត្យស្តីពី នីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល និងគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន ។
- រៀបចំប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀន។
- រៀបចំប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន ។
- រៀបចំបង្កើតគណៈកម្មាធិការជាតិ ទទួលបន្ទុកកិច្ចការព្យាបាល ថែទាំបន្ត ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និសមាហរណកម្មអ្នកញៀនគ្រឿងញៀន ។
- ចុះជួយរៀបចំផែនការត្រួតពិនិត្យគ្រឿងញៀន របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានីភ្នំពេញ ។

## III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែកញ្ញា ឆ្នាំ២០១៤

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននឹងបន្តសម្របសម្រួល ជំរុញអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

## ១. ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១.** ស្នើសុំទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តស្ទឹងត្រែង ដើម្បីផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីសភាអ៊ីនធឺណែតនៃស្ថានីយទូរទស្សន៍ CTN និង CNC ស្តីពីសកម្មភាព និងលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀននៅក្នុងភូមិសាស្ត្ររបស់ខេត្តស្ទឹងត្រែង ។

**១.២.** បន្តកិច្ចសហការជាមួយក្រុមហ៊ុន Musashi Advertising Co., LTD ដើម្បីផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀននៅរាជធានីភ្នំពេញ តាមរយៈការបញ្ចាំងរូបភាព និងភាពយន្តខ្លី នៅលើរថយន្តចល័ត ។

**១.៣.** បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន និងការបង្ការទប់ស្កាត់ការប្រើប្រាស់ ការធ្វើអាជីវកម្មផលិតផលស៊ីហ្សា និង បារីអេឡិចត្រូនិច នៅតាមរាជធានី-ខេត្តទូទាំងប្រទេស ។

**១.៤.** សហការជាមួយក្រសួងទេសចរណ៍ ដើម្បីរៀបចំផលិតបន្ថែមនូវស្ទីកឃ័រ (Sticker) ផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន អេដស៍ ការប្រើប្រាស់អាវុធ និងការជួញដូរមនុស្ស ។

**១.៥.** បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករតន្ត្រីករនិងវិស័យឯកជន ដើម្បីជំរុញការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមប្រព័ន្ធផ្សព្វផ្សាយនានា ។

**១.៦.** បន្តជំរុញការងារបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមក្រសួង-ស្ថាប័ន រោងចក្រ សហគ្រាស និងនៅតាមសហគមន៍ ។

**១.៧.** ត្រៀមជួបពិភាក្សាការងារជាមួយក្រសួងធម្មការ និងសាសនា លើការងារអប់រំផ្សព្វផ្សាយ ។

**១.៨.** បន្តផ្តល់ការគាំទ្រកម្មវិធីមហោស្រពតន្ត្រី ចម្រៀងកុមារពានរង្វាន់ក្រសួងព័ត៌មាន ឆ្នាំ២០១៤ ។

**១.៩.** សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តគោលដៅ និងវិស័យឯកជន ដើម្បីបន្តរៀបចំកម្មវិធីប្រគំតន្ត្រីអប់រំពីបញ្ហាគ្រឿងញៀន ។

## ២. ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

**២.១.** បន្តជំរុញក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ក្នុងការបង្កើតសេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

**២.២.** បន្តការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

**២.៣.** បន្តការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ដើម្បីបង្កើនការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយឱសថ មេតាដូន នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

**២.៤.** ត្រៀមចាត់បញ្ជូនមន្ត្រីចំនួន ០៣ រូប ទៅទទួលវគ្គបណ្តុះបណ្តាល លើកទី៦ ស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនតាមស្តង់ដារ (ថ្ងៃទី២៥/៨-០៥/៩/២០១៤ នៅវិទ្យាស្ថាន Thanyarak ប្រទេសថៃ) ។

## ៣. ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់

**៣.១.** បន្តរៀបចំវគ្គបណ្តុះបណ្តាលដល់កងយោធពលខេមរភូមិន្ទ (យោធភូមិភាគ៣ ខេត្តកំពង់ស្ពឺ ថ្ងៃទី ០៩/៩/២០១៤ ចំនួន ១៥០ នាក់) និង (យោធភូមិភាគពិសេស ខេត្តកណ្តាល ថ្ងៃទី១១/៩/ ២០១៤ ចំនួន ១៥០ នាក់)។

**៣.២.** ត្រៀមចូលរួមកិច្ចប្រជុំ GIZ/INI ស្តីពីការសន្ទនាក្រៅផ្លូវការអំពីគោលនយោបាយគ្រឿងញៀនអាស៊ាន (២៩-៣០ ខែកញ្ញា ឆ្នាំ២០១៤ នៅប្រទេសឥណ្ឌា)។

**៣.៣.** បន្តរៀបចំវគ្គបណ្តុះបណ្តាល (វគ្គពីរឆ្នាំ២០១៤) ដល់ចៅសង្កាត់ និង នគរបាលប៉ុស្តិ៍ ចំនួន ១២៦ របស់ខណ្ឌ ៧ មករា, ពោធិ៍សែនជ័យ និងខណ្ឌចំការមន (ថ្ងៃទី១១-១២/៩/២០១៤)។

**៣.៤.** បន្តរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមប្រព័ន្ធកុំព្យូទ័រ ដល់មន្ត្រីអនុវត្តន៍ច្បាប់រាជធានីភ្នំពេញ ចំនួន ១២ រូប (ថ្ងៃទី០១-០៥/៩/២០១៤ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ)។

**៣.៥.** ត្រៀមទទួលសម្ភារៈ (វិទ្យុទាក់ទង) សម្រាប់ការិយាល័យ BLO ចំនួន ៥ កន្លែងនៅ ច្រកជ្រៃធំ ខេត្តកណ្តាល, ច្រកប៉ោយប៉ែត (ខេត្តបន្ទាយមានជ័យ), ច្រកដូង (ខេត្តបាត់ដំបង), ច្រកព្រំ (ខេត្តប៉ៃលិន) និង ច្រកចាំយាម (ខេត្តកោះកុង)។

**៣.៦.** ត្រៀមរៀបចំបង្កើតក្រុមការងារទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងកាត់ តាមច្រកអាកាសយានដ្ឋានអន្តរជាតិ ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សេងៗ

**៤.១.** បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

**៤.២.** សិក្សាស្រាវជ្រាវនិងប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុថ្មី ដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដើម្បីដាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៤.៣.** បន្តជំរុញនីតិវិធីក្នុងការប្រគល់និងទទួលប្រេងម្រះព្រៅភ្នំ ចំនួន ១.៧០០ លីត្រ និង ១២៣ គ.ក្រ ទៅឲ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម ព្រមទាំងសហការជាមួយខេត្តពោធិ៍សាត់ ស្រាវជ្រាវករណីប្រេងម្រះព្រៅភ្នំ ចំនួន ១៣៩ ប៊ីដុង ដែលសមត្ថកិច្ចខេត្តពោធិ៍សាត់រកឃើញកាលពីថ្ងៃទី១៧, ១៨ និងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង

**៥.១.** សម្របសម្រួលជាមួយប្រទេសជិតខាង ក្នុងការជំរុញកិច្ចប្រជុំឲ្យបានទៀងទាត់ រវាងបណ្តាខេត្តនិងខេត្តជាប់ព្រំដែន កម្ពុជា-ថៃ / កម្ពុជា-វៀតណាម / កម្ពុជា-ឡាវ ។

**៥.២.** សម្របសម្រួលជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀនវៀតណាម និងឡាវ ដើម្បីរៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ ទៅកាន់ប្រទេសវៀតណាម និង ឡាវ ។

***៥.៣.*** សម្របសម្រួលជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដើម្បីចាត់បញ្ជូនមន្ត្រីទៅចូលរួមក្នុងពិធីបើកការិយាល័យអាស៊ាន ASEAN-NARCO (ថ្ងៃទី១៥-១៨/៩/២០១៤ នៅទីក្រុងបាងកក ប្រទេសថៃ) ។

***៥.៤.*** ត្រៀមចូលរួមកិច្ចប្រជុំត្រៀម សម្រាប់កិច្ចប្រជុំគណៈកម្មាធិការចម្រុះតំបន់ត្រីកោណអភិវឌ្ឍន៍ លើកទី៩ និងកិច្ចប្រជុំពាក់ព័ន្ធ (ថ្ងៃទី០១/៩/ ២០១៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម) ។

***៥.៥.*** ត្រៀមចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម លើកទី៩ និងកិច្ចប្រជុំពាក់ព័ន្ធ (ថ្ងៃទី០៨-១២/៩/ ២០១៤ នៅទីក្រុងសៀមរាប) ។

## ***៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ***

***៦.១.*** សម្របសម្រួលជាមួយអង្គការ JICA ដើម្បីចាត់បញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យបទល្មើសគ្រឿងញៀន ដែលនឹងត្រូវធ្វើនៅប្រទេសជប៉ុន នាថ្ងៃទី៣១ ខែសីហា ដល់ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៤ ។

***៦.២.*** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីចាត់បញ្ជូនមន្ត្រីទៅចូលរួមសន្និសីទអនុវត្តន៍ច្បាប់អនុ-តំបន់ នៅទីក្រុងគុនមិញ ប្រទេសចិន (២៤-២៥/៩/២០១៤) ។

***៦.៣.*** ត្រៀមចូលរួមក្នុងកិច្ចប្រជុំ APICC (នៅប្រទេសកូរ៉េ ថ្ងៃទី៣០/៩/២០១៤) ។

***៦.៤.*** សម្របសម្រួលជាមួយស្ថាប័ន GIZ ដើម្បីបញ្ជូនតំណាងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅចូលរួមកិច្ចប្រជុំ GIZ/INI ស្តីពីការសន្ទនាក្រៅផ្លូវការអំពីគោលនយោបាយគ្រឿងញៀនអាស៊ាន (២៩-៣០ ខែកញ្ញា ឆ្នាំ២០១៤ នៅប្រទេសឥណ្ឌា) ។

***៦.៥.*** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំពិធីប្រគល់-ទទួលសម្ភារៈ សម្រាប់កម្មវិធីបណ្តុះបណ្តាលចល័តស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន ។

***៦.៦.*** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំពិធីប្រគល់-ទទួលសម្ភារៈ សម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ពីគម្រោង PATROL របស់អង្គការ UNODC ។

***៦.៧.*** សម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនចិន ដើម្បីត្រៀមដំណើរទស្សនកិច្ចផ្លូវការជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ អញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

***៦.៨.*** ត្រៀមរៀបចំកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន (ធ្វើនៅកម្ពុជា ។

## ***៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ***

***៧.១.*** បន្តការកែសម្រួលអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំង គ្រឿងញៀន ។

***៧.២.*** បន្តពិនិត្យលើការរៀបចំដាក់បញ្ចូលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ ។

***៧.៣.*** បន្តការពិនិត្យ និងកែសម្រួល លើសេចក្តីព្រាងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ។

***៧.៤.*** បន្តការរៀបចំអនុក្រឹត្យស្តីពី នីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល និងគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន ។

***៧.៥.*** បន្តការរៀបចំប្រកាសស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀន ។

***៧.៦.*** បន្តការរៀបចំប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន ។

***៧.៧.*** បន្តការរៀបចំបង្កើតគណៈកម្មាធិការជាតិ ទទួលបន្ទុកកិច្ចការព្យាបាល ថែទាំបន្ត ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និសមាហរណកម្មអ្នកញៀនគ្រឿងញៀន ។

***៧.៨.*** បន្តការចុះជួយរៀបចំផែនការត្រួតពិនិត្យគ្រឿងញៀន របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានីភ្នំពេញ ។

**អគ្គលេខាធិការ**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣

  "ដើម្បីជូនជ្រាប"
- ក្រសួង សមាជិក អ.ជ.ប.គ.៣
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

  "ដើម្បីមុខការ"
- ឯកសារ